**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ០១ .បប.**

# បទបញ្ជា

## ស្តីអំពី

## វិធានការបញ្ឈប់ការបិទខ្ទប់ការតភ្ជាប់បណ្តាញសេវាទូរស័ព្ទគ្នា ទៅវិញទៅមករវាងប្រតិបត្តិករទូរស័ព្ទមួយទៅប្រត្តិបត្តិករទូរស័ព្ទមួយទៀត

ឲឲឲ៚៙៙៙

តាមរយៈការអនុវត្តគោលនយោបាយបើកទូលាយរបស់រាជរដ្ឋាភិបាល នៅបណ្តាឆ្នាំចុងក្រោយនេះវិស័យទូរគមនាគមន៍បានដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ជាពិសេសមានក្រុមហ៊ុនឯកជន ជាច្រើនបានចូលមកវិនិយោគលើវិស័យទូរគមនាគមន៍នៅកម្ពុជា ។

ស្របពេលគ្នានិងកំណើននៃការវិនិយោគរបស់ផ្នែកឯកជនលើវិស័យទូរគមនាគន៍ និងការកើនឡើងនៃអ្នកប្រើប្រាស់ទូរស័ព្ទចល័ត ទីផ្សារទូរគមនាគមន៍នៅកម្ពុជាបានបោះជំហានចូលទៅក្នុងការប្រកួតប្រជែងគ្នា យ៉ាងស្វិតស្វាញ រវាងប្រតិបត្តិករទូរគមនាគមន៍ទាំងអស់ ។

នាពេលថ្មីៗ រាជរដ្ឋាភិបាលសង្កេតឃើញថា ការតភ្ជាប់បណ្តាញគ្នាទៅវិញទៅមករវាងប្រតិបត្តិករទូរគមនាគមន៍មួយទៅប្រតិបត្តិករទូរគមនាគមន៍មួយទៀត ឬ ការហៅទូរស័ព្ទឆ្លងប្រព័ន្ធនៅជួបប្រទះការលំបាក ស្មុគស្មាញបំផុតដែលជាហេតុបង្កឱ្យមានផលវិបាកជាច្រើនចំពោះអ្នកប្រើប្រាស់ ។

កន្លងមកនេះក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍បានខិតខំប្រឹងប្រែងព្យាយាមរិះរកគ្រប់មធ្យោបាយធ្វើអន្តរាគមន៍ដោះស្រាយបាតុភាពនេះបន្តបន្ទាប់រួចមកហើយ ប៉ុន្តែពុំទាន់បានទទួលលទ្ធផលផ្លែការល្អនៅឡើយ ។

ក្នុងមូលហេតុខាងលើនេះ ដើម្បីធានាឱ្យបាននូវការផ្តល់សេវាទូរគមនាគមន៍ប្រកបដោយគុណភាពល្អ ទាំងក្នុងប្រព័ន្ធក៏ដូចក្រៅប្រព័ន្ធ សំដៅចៀសវាងឱ្យបាននូវការថ្នាំងថ្នាក់ពីអ្នកប្រើប្រាស់ រាជរដ្ឋាភិបាលសំរេច ដាក់បញ្ជាដូច ខាងក្រោម ៖

១) ប្រតិបត្តិករទូរគមនាគមន៍ ទាំងសហគ្រាសរដ្ឋនិងឯកជនត្រូវធានាលើការផ្តល់សេវាទូរគមនាគមន៍ប្រកបដោយគុណភាពល្អជូនតិថិជនរបស់ខ្លួន ។

២) គ្រប់ប្រតិបត្តិករទូរគមនាគមន៍ត្រូវតែបញ្ឈប់ជាបន្ទាន់នូវការប្រកួតប្រជែងដណ្តើមអតិថិជនគ្នាតាមរយៈការរាំងខ្ទប់ការតភ្ជាប់បណ្តាញគ្នាទៅវិញទៅមក ។

៣) ការកំណត់ថ្លៃសេវារបស់គ្រប់ប្រតិបត្តិករទូរគមនាគមន៍ត្រូវផ្អែកលើមូលដ្ឋានថ្លៃដើមជាក់ស្តែងដែលទទួលស្គាល់ដោយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ។

៤) ការតភ្ជាប់បណ្តាញគ្នាទៅវិញទៅមកត្រូវអនុវត្តឱ្យបានម៉ឺងម៉ាត់តាមខ្លឹមសារនៃប្រកាសរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍លេខ ២០៦ប.ទ. ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ២០០៩ ។

៥) ការប្រកួតប្រជែងគ្នាត្រូវប្រព្រឹត្តទៅក្នុងក្របខណ្ឌខ្លឹមសារនៃសារាចរអន្តរក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍លេខ ១២៧៧ ស.ហ.វ. ប.ទ. ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ ២០០៩ ។

៦) ការតភ្ជាប់បណ្តាញគ្នាទៅវិញទៅមករវាងប្រតិបត្តិករទូរគមនាគមន៍ទាំងអស់ត្រូវឆ្លងកាត់តាមមជ្ឈមណ្ឌលកណ្តាលនៃទូរគមនាគមន៍កម្ពុជា ។

ទូរគមនាគមន៍កម្ពុជាដែលជាអង្គភាពគ្រប់គ្រងចរន្តសេវាទូរគមនាគមន៍ឆ្លងកាត់ត្រូវផ្តល់ជូនក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ឱ្យបានទៀងទាត់និងជាប្រចាំនូវព័ត៌មានស្តីអំពីស្ថានភាពត្រាហ្វិក (Traffic) ដែលមានការបិទខ្ទប់ ។

បន្ថែមលើខ្លឹមសារនៃសារាចរអន្តរក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ លេខ ១២៧៧ ស.ហ.វ. ប.ទ. ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០០៩ ព្រមទាំងប្រកាសរបស់ទូរគមនាគមន៍លេខ ២០៦ ប.ទ. ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០០៩ រាជរដ្ឋាភិបាលនឹងចាត់វិធានការយ៉ាងម៉ឺងម៉ាត់ ចំពោះ ប្រតិបត្តិករ ទូរគមនាគមន៍ណា ដែលពុំគោរពតាមបទបញ្ជានេះ ហើយនៅតែបន្តការបិទខ្ទប់ការតភ្ជាប់ បណ្តាញគ្នាទៅវិញទៅមក ឬ ធ្វើ សកម្មភាពប្រកួតប្រជែងគ្នាដោយពុំស្មោះត្រង់នាំឱ្យច្របូកច្របល់ស្ថានភាពទីផ្សារទូរគមនាគមន៍នៅកម្ពុជា ដូចខាង ក្រោម ៖

ទី ១) សងការខាតបង់ជាប្រាក់ជូនភាគីជាដៃគូក្នុងកិច្ចសន្យា និង ផលប៉ះពាល់ចំពោះការបាត់បង់ចំណូលថវិការដ្ឋ

ទី ២) ផ្តាច់បណ្តាញទាំងអស់ចេញពីមជ្ឈលមណ្ឌលឆ្លងកាត់.

ទី ៣) ផ្អាកអាជ្ញាប័ណ្ណអាជីវកម្មបណ្តោះអាសន្ន ឬ ដកហូតអាជ្ញាប័ណ្ណអាជីវកម្មជាស្ថាពរ

ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ ក្រសួងប្រសណីយ៍ និង ទូរគមនាគមន៍ ក្រសួង ស្ថាប័ន ខេត្ត រាជធានី និង អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធព្រម ទាំងប្រតិបត្តិករ ទូរគមនាគមន៍ទាំងអស់ត្រូវអនុវត្តតាមបទបញ្ជានេះឱ្យបានមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួងស្ថាប័ន
- គ្រប់សាលាខេត្ត រាជធានី
- ឯកសារ កាលប្បវត្តិ